
- ចំពោះការសាងសង់ នឹងមានការបញ្ចេញ ឬបន្សល់នូវកាកសំណល់មួយចំនួន តើក្រុមហ៊ុនមានវិធានការដោះស្រាយយ៉ាងណា?



Draft


រូបភាព៥.១៤៖ លោក សូស សុផល អនុប្រធានមន្ទីរបរិស្ថានខេត្ត ក្នុងកិច្ចប្រជុំពិគ្រោះយោបល់

៥.៦.៦ ការបញ្ចេញមតិយោបល់របស់នាយករដ្ឋបាលស្រុកសំរោងទង

លោក ញ៉ែន មន្នីរតនៈ នាយករដ្ឋបាលស្រុកសំរោងទងបានមានមតិយោបល់ ជុំវិញការរៀបចំបោយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង គម្រោងធ្វើខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុល របស់ក្រុមហ៊ុន Alex Corporation ក្នុងកិច្ចប្រជុំនៅមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺកាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ មានដូចតទៅ៖

- លោកបានមានជាមតិចូលរួមថា អាជ្ញាធរសូមធ្វើការគាំទ្រយ៉ាងពេញទំហឹង ចំពោះការអភិវឌ្ឍន៍នេះ។

- ហើយលោកបានបន្តទៀតថា រាល់បញ្ហាដែលប៉ះពាល់ដលប្រជាជន សូមឱ្យមានដំណោះស្រាយទៅតាមប្រភេទដី និងលំនៅដ្ឋានដែលអាចទទួលយកបានទាំងក្រុមហ៊ុន និងប្រជាជន។




រូបភាព៥.១៥៖ លោក ញ៉ែន មន្ទីរតន: នាយករដ្ឋបាលស្រុកសំរោងទង ក្នុងកិច្ចប្រជុំពិគ្រោះយោបល់

៥.៦.៧ ការបញ្ចេញមតិយោបល់របស់នាយកឧទ្យានជាតិគីរីរម្យ

លោក ជា រ័ត្ន នាយកឧទ្យានជាតិគីរីរម្យ បានមានមតិយោបល់ជុំវិញការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង គម្រោងធ្វើខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ក្នុងកិច្ចប្រជុំនៅមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺកាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ មានដូចតទៅ៖

- លោកបានមានជាសំនួរ ពាក់ព័ន្ធជាមួយនឹងពេលដែលរៀបចំដំឡើងគម្រោង ធ្វើឱ្យប៉ះពាល់ដល់អ្វរ ព្រៃការពារ នៅពេលដែលជីកគ្រឹះ និងគ្រឿងតម្លើង។ តើក្រុមហ៊ុនមានវិធានការយ៉ាងណាចំពោះបញ្ហានេះ?
- គាំទ្រ និងសហការជាមួយក្រុមហ៊ុនជានិច្ច។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com




Draft

រូបភាព៥.១៦៖ លោក ដា តែ្ង នាយកឧទ្យានជាតិគីរីរម្យ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់

៥.៦.៨ ការបញ្ចេញមតិយោបល់របស់អតិថិជនរងស្រុកគងពិសី

លោក ចែម គីនឥីមវន្ថី អភិបាលរងស្រុកគងពិសីបានមានមតិយោបល់ជុំវិញរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង គម្រោងធ្វើខ្សែបញ្ជូនអគ្គិសនី តង់ស្យុងខ្ពស់ ២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ក្នុងកិច្ចប្រជុំនៅមន្ទីរបរិស្ថាន ខេត្តកំពង់ស្ពឺកាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ មានដូចតទៅ៖

- លោកមានជាមតិទាក់ទងនឹងការផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ប្រជាជន ឱ្យបានទូលំទូលាយ ដើម្បីឱ្យប្រជាជនអាចដឹងកាន់តែច្បាស់ពីគម្រោង និងអាចកាត់បន្ថយការប៉ះពាល់ពីការអូសខ្សែបញ្ជូនអគ្គិសនីនេះ។
- លោកបានបន្តទៀតថាបើមានផលប៉ះពាល់ សូមឱ្យក្រុមហ៊ុនមេត្តាដោះស្រាយដល់ប្រជាជនទៅតាមភាពជាក់ស្តែងទៅនឹងទំហំនៃការខូចខាត។



Draft

រូបភាព៥.១៧៖ លោក ចែម ភីនទីមរទ្ធី អភិបាលរងស្រុកគងពិសី ក្នុងកិច្ចប្រជុំពិគ្រោះយោបល់

៥.៦.៩ ការបញ្ចេញមតិយោបល់របស់មន្ត្រីពន្ធដារខេត្ត

លោក សុខ ចំរើន មន្ត្រីពន្ធដារខេត្តកំពង់ស្ពឺ បានមានមតិយោបល់ ជុំវិញរបាយការណ៍វាយតម្លៃហោតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង គម្រោងធ្វើខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០ គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ក្នុងកិច្ចប្រជុំនៅមន្ទីរបរិស្ថាន ខេត្តកំពង់ស្ពឺកាលពីថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០១៥ មានដូចតទៅ៖

- លោកមានជាសំនួរ ទៅលើថាតើការអនុវត្តគម្រោងនេះ បានប៉ះពាល់ដល់វិស័យសេដ្ឋកិច្ចយ៉ាងណាខ្លះ?
- ហើយលោកបានបញ្ជាក់ថា ការវាយតម្លៃដីធ្លី មិនមែនជាតួនាទីខាងពន្ធដារទេ។ តាមបទពិសោធន៍កន្លងមកត្រូវមានអង្គភាពអនុកម្មាការវាយតម្លៃ ជាអ្នកវាយតម្លៃដីគឺទាមទារឱ្យមានការចូលរួមពី មន្ទីរកសិកម្ម មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងពន្ធដាជាអ្នកយកពន្ធ។



រូបភាព៥.១៨៖ លោក សុខ ចំរើន មន្ត្រីពន្ធដាខេត្តកំពង់ស្ពឺ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់

៥.៦.១០ ការបញ្ជាក់មតិយោបល់របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លោក ចិន សំបាន អនុប្រធានការិយាល័យរដ្ឋបាលមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានមានមតិយោបល់ជុំវិញរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង គម្រោងធ្វើខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ក្នុងកិច្ចប្រជុំនៅមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺកាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ មានដូចតទៅ៖

- លោកមានសំណើតែមួយ គឺសូមឱ្យក្រុមហ៊ុនធ្វើការសាងសង់បង្គោលដោយគោរពតាមច្បាប់រៀបចំដែនដីនគរូបនីយកម្ម។
- បើមានដីប៉ះពាល់សូមឱ្យមានការដោះស្រាយដោយសន្តិវិធី
- សូមគាំទ្រ និងត្រៀមខ្លួនក្នុងការសហការជាមួយក្រុមហ៊ុនក្នុងការចុះដោះស្រាយដីប៉ះពាល់ប្រជាជន និងពេលសាងសង់។



រូបភាព៥.១៩៖ លោក ប៊ិន សំបាន អនុប្រធានការិយាល័យរដ្ឋបាលមន្ទីររៀបចំដែនដី

Draft


៥.៦.១១ ការបង្ហាញមតិយោបល់របស់តំណាងក្រុមហ៊ុន Alex Corporation

លោក តាន់ ទីន តំណាងក្រុមហ៊ុន Alex Corporation បានមានមតិយោបល់លើការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង គម្រោងធ្វើខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ក្នុងកិច្ចប្រជុំនៅមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៥ មានដូចតទៅ៖

- គម្រោងខ្សែបញ្ជូនអគ្គិសនីនេះ ជាគម្រោងដែលត្រូវបានលើកទឹកចិត្តពីរាជរដ្ឋាភិបាលហៅថា BOT (Build Operation Tranfer) ព្រោះគម្រោខ្សែបញ្ជូនអគ្គិសនីភាគច្រើនជាគម្រោងដែលវិនិយោគដោយក្រុមហ៊ុនពីបរទេស ទើបតែមានគម្រោងនេះមួយទេដែលមានម្ចាស់គម្រោងក្នុងស្រុក។
- គម្រោងខ្សែបញ្ជូនអគ្គិសនីនេះ ក្រុមហ៊ុនមានប្លង់រួចជាស្រេច ទាំងប្លង់បង្គោលក្នុងការសាងសង់បង្គោល និងខ្សែបញ្ជូន។ ម៉្យាងទៀតគម្រោងប្លង់អូសខ្សែបញ្ជូននេះ ក្រុមហ៊ុនបានសិក្សារួចជាស្រេច ដើម្បីបញ្ចៀសការប៉ះពាល់លំនៅដ្ឋាន និងតំបន់ទីប្រជុំជន។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

- រាល់ការប៉ះពាល់ទាំងឡាយក្រុមហ៊ុន Alex Coporation បានសហការជាមួយក្រុមហ៊ុនទីប្រឹក្សាឯករាជដើម្បីវាយតម្លៃនូវការប៉ះពាល់ទាំងបរិស្ថាន និងសង្គម។ ម៉្យាងទៀតការសិក្សាក៏បានរួមបញ្ចូលនូវការសិក្សាពីតម្លៃដី តម្លៃស្រែចម្ការ ដែលរងការប៉ះពាល់តាមបណ្តាយគន្លងខ្សែបញ្ជូនអគ្គិសនីនេះ។
- ក្រុមហ៊ុនក៏មានផែនការកាត់បន្ថយនូវហេតុប៉ះពាល់ដែលអាចកើតមាន ដូចជាការគ្រប់គ្រងការរំខានដោយសំឡេង ការបំពុលទឹក និងការគ្រប់គ្រងសំណង់រឹង-រាងទាំងឡាយ ដើម្បីឱ្យហេតុប៉ះពាល់ទាំងអស់នេះដល់កម្រិតតិចបំផុត។
- គ្រប់មតិយោបល់ និងអនុសាសន៍ក្នុងអង្គប្រជុំនៅក្នុងថ្ងៃនេះខ្ញុំបាទនឹងដាក់ចូលកំណត់ហេតុនឹងដាក់ជូនក្រុមហ៊ុនពិនិត្យ។
- ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណដល់អាជ្ញាធរខេត្តកំពង់ស្ពឺ ដែលមានគាំទ្រចំពោះគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីនេះ និងចូលរួមសហការជាមួយក្រុមហ៊ុន។



Draft

រូបភាព៥.២០៖ លោក តាន់ ទីន តំណាងក្រុមហ៊ុន Alex Corporation ក្នុងកិច្ចប្រជុំពិគ្រោះយោបល់



#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

៥.៧ សង្ខេបលទ្ធផលនៃការប្រជុំពិភាក្សាពិគ្រោះយោបល់នៅមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ

តាមរយៈការប្រជុំពិភាក្សាពិគ្រោះយោបល់នៅមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ ដែលមាន **ឯក ឧត្តម ខ៊ី សំណាង** អភិបាលរងខេត្ត ជាគណៈអធិបតី និងមានក្រុមហ៊ុនទីប្រឹក្សា គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ ជាអ្នកធ្វើបទបង្ហាញ ព្រមទាំងមានមន្ទីរ និងស្ថាប័នដែលពាក់ជាច្រើនបានមកផ្តល់យោបល់ និងអនុសាសន៍ផ្សេងៗដែលទាក់ទងនឹងគម្រោងធ្វើខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ ២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ដែលមានទីតាំងពីអនុស្ថានីយ៍ស្វីងហាវទៅអនុស្ថានីយ៍អគ្គិសនីខាងលិចរាជធានីភ្នំពេញ។ បានបង្ហាញឱ្យឃើញថាការរៀបចំរបាយការណ៍ និងការធ្វើបទបង្ហាញរបស់ក្រុមហ៊ុនទីប្រឹក្សាបានល្អប្រសើរអាចទទួលយកបាន។ ខាងក្រោមមានចំនុចមួយចំនួនត្រូវបំពេញបន្ថែម ដែលជាសំណើពីខាងមន្ទីរពាក់ព័ន្ធរួមមាន៖

- ក្រុមហ៊ុនត្រូវគិតគូរពីបញ្ហាបំពាក់ស្លាកសញ្ញាហាមឃាត់នៅតាមបង្គោល ឬខ្សែអគ្គិសនី ដើម្បីឱ្យប្រជាជនបានដឹង ដែលអាចទប់ស្កាត់រាល់ការគ្រោះថ្នាក់ពីការឆក់អគ្គិសនី។
- ត្រូវបង្កើតវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ប្រជាជនឱ្យបានទូលំទូលាយចំពោះការសាងសង់គម្រោងនេះ និងផលប៉ះពាល់ជាយថាហេតុនៅថ្ងៃអនាគត។
- បង្គោលអគ្គិសនីគួរតែបំពាក់សំណាញ់ការពារហាមឃាត់មិនឱ្យក្មេងឡើងលេង និងបង្គោលដែលអាចនាំឱ្យឆក់ ឬធ្លាក់។
- ទាក់ទងនឹងសំណល់ដែលបញ្ចេញពីការសាងសង់ សូមឱ្យមានការគ្រប់គ្រងឱ្យបានល្អជាពិសេសប៉ះពាល់ដោយសម្លេងក្នុងពេលអនុវត្តន៍។
- យ៉ាងណាមិញ សូមឱ្យកាត់បន្ថយផលប៉ះពាល់ដល់តូចបំផុត ហើយបើប៉ះពាល់ដី ឬសម្បត្តិប្រជាជន សូមឱ្យមានការវាយតម្លៃឱ្យបានសមរម្យ និងអាចទទួលយកបានទាំងប្រជាជន និងក្រុមហ៊ុន។
- ហើយជាមតិចុងក្រោយអាជ្ញាធរ និងមន្ទីរដែលពាក់ព័ន្ធខេត្តកំពង់ស្ពឺបានសម្តែងនូវកិច្ចសហការ និងគាំទ្រយ៉ាងពេញទំហឹងចំពោះការអនុវត្តគម្រោងខ្សែបញ្ជូនអគ្គិសនីនេះដែលជាចំណែកចូលរួមក្នុងការអភិវឌ្ឍប្រទេសផងដែរ។ គ្រប់មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរបន្តចូលរួមសហការ និងគាំទ្រលើការអនុវត្តគម្រោងនេះឱ្យបានរលូន និងឆាប់រហ័ស។

Draft


Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

តារាង៥.៣៖ សេចក្តីសន្ទេបយោបល់ និងសំនូមពរនៃការពិគ្រោះយោបល់នៅមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ


ល.រ	ឈ្មោះ	តួនាទី	រូបភាព	គាំទ្រការអនុវត្ត	មិនគាំទ្រការអនុវត្ត	មតិយោបល់/អនុសាសន៍
១	ឯកឧត្តម វ៉ី សំណាង	អភិបាលរង ខេត្តកំពង់ស្ពឺ		✓		• ក្រុមហ៊ុនត្រូវគិតគូរពីបញ្ហាបំពាក់ស្លាកសញ្ញាហាមឃាត់នៅតាមបង្គោល ឬខ្សែអគ្គិសនី។ • ត្រូវបង្កើតវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយ ដល់ប្រជាជនឱ្យបានទូលំទូលាយ។ • បង្គោលអគ្គិសនី គួរតែបំពាក់សំណាញ់ការពារហាមឃាត់មិនឱ្យក្មេងឡើងលេង និងបង្គោល ។ • សំណល់ដែលបញ្ចេញពីការសាងសង់ សូមឱ្យមានការគ្រប់គ្រងឱ្យបានល្អ ។ • កាត់បន្ថយផលប៉ះពាល់ដល់តួចបំផុតហើយបើប៉ះពាល់ដី ឬសម្បត្តិប្រជាជន។ • សហការ និងគាំទ្រយ៉ាងពេញទំហឹងចំពោះការអនុវត្តគម្រោងខ្សែបញ្ជូនអគ្គិសនីនេះ។
២	លោក ហោង គួន	ប្រធានមន្ទីរបរិស្ថានខេត្តកំពង់ស្ពឺ		✓		• នៅពេលដែលខ្សែអគ្គិសនីអូសឆ្លងកាត់ឧទ្យានជាតិ ខាងអគ្គិសនីត្រូវសុំការអនុញ្ញាតពីឧទ្យានជាតិ។ • សុវត្ថិភាពបង្គោលគួរធ្វើរបង និងដាក់ស្លាកសញ្ញាឆ្លងកាត់ព្រោះធ្លាប់មានបទពិសោធន៍កន្លងមក ដោយប្រជាជនឆក់ស្លាប់។ • ចំពោះចន្លោះបង្គោល ៤០០ ទៅ ៤៥០ អាចដួលប៉ះពាល់ដល់ប្រជា

Draft

E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

						ជន នៅពេលដែលមានខ្យល់ខ្លាំង។ ដូច្នេះក្រុមហ៊ុនគួរមានវិធានការយ៉ាងណាចំពោះបញ្ហានេះ?
៣	លោក ស្ងួន សារ៉ុន	អភិបាលរង ស្រុកភ្នំស្រួច				• លោកចង់ឱ្យបញ្ជាក់ឱ្យបានច្បាស់ចំពោះទំហំបង្គោលនីមួយៗ មានទំហំប៉ុន្មាន? • សូមឱ្យក្រុមហ៊ុន ធ្វើការបណ្តុះបណ្តាលប្រជាជនឱ្យបានដឹង និងកំឱ្យមានការភ័យខ្លាចនឹងគម្រោងនេះ។ • ក្រុមហ៊ុនគួរតែបំពាក់សំណាញ់ដើម្បីបាំងកុំឱ្យក្មេងឡើងលេងលើបង្គោលដែលនាំឱ្យមានគ្រោះថ្នាក់។
៤	លោក ពុត សុភ័ក	ប្រធានអគ្គិសនីខេត្តកំពង់ស្ពឺ		✓		• រាជរដ្ឋាភិបាល តាមរយៈក្រសួងរ៉ែ និងថាមពល អគ្គិសនីកម្ពុជាបានសហការជាមួយក្រុមហ៊ុន Alex Corporation យ៉ាងជិតស្និត។ • ជាបទពិសោធន៍កន្លងមក បញ្ហាគ្រោះថ្នាក់របស់ប្រជាជន ដែលឡើងលេង ឬប៉ះពាល់បង្គោលភ្លើងតែងតែកើតមាន ទោះបីជាមានស្លាកសញ្ញាហាមឃាត់ក៏ដោយ។ • តាមគំនិតខ្ញុំការផ្សព្វផ្សាយ ដល់ប្រជាជនឱ្យមានដឹងលឺពីប្រការគ្រោះថ្នាក់ដោយការឡើងរលង ឬប៉ះពាល់បង្គោលអគ្គិសនីនេះ។
៥	លោក សួស សុផល	អនុប្រធាន មន្ទីរបរិស្ថាន ខេត្តកំពង់ស្ពឺ		✓		• បញ្ហាសំឡេងខ្ទរខ្ទាន ក្នុងពេលអនុវត្តន៍ ថាតើក្រុមហ៊ុនមានវិធានការយ៉ាងណាដើម្បីកាត់បន្ថយ កុំឱ្យមានការរំខានខ្លាំងដល់ប្រជាជន និងសត្វព្រៃផងដែរ? • ការបញ្ចេញ ឬបន្សល់នូវកាកសំណល់មួយចំនួន តើក្រុមហ៊ុនមានវិធានការដោះស្រាយយ៉ាងណា?

Draft

៦	លោក ញ៉ែន មន្នីរតន:	នាយករដ្ឋបាលស្រុកសំរោងទង		✓		• រាល់បញ្ហាដែលប៉ះពាល់ដល់ប្រជាជន សូមឱ្យមានដំណោះស្រាយទៅតាមប្រភេទដី និងលំនៅដ្ឋាន ។ • អាជ្ញាធរសូមធ្វើការគំទ្រយ៉ាងពេញទំហឹង ចំពោះការអភិវឌ្ឍនេះ។
៧	លោក ដា វ៉ែត	នាយកឧទ្យានជាតិគីរីរម្យ.		✓		• ពាក់ព័ន្ធជាមួយនឹងពេលដែលរៀបចំដំឡើងគម្រោង ធ្វើឱ្យប៉ះពាល់ដល់ អូរ ព្រៃការពារ នៅពេលដែលជីកគ្រឹះ និងគ្រឿងដំឡើង។ តើក្រុមហ៊ុន មានវិធានការយ៉ាងណាចំពោះបញ្ហានេះ? • គាំទ្រ និងសហការជាមួយក្រុមហ៊ុនជានិច្ច។
៨	លោក ចែម កីន ទីមវ៉ឺ	អភិបាលរងស្រុកគងពិសី		✓		• ការផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ប្រជាជន ឱ្យបានទូលំទូលាយដើម្បីឱ្យប្រជាជនអាចដឹងកាន់តែច្បាស់ពីគម្រោង។ • បើមានផលប៉ះពាល់ សូមឱ្យក្រុមហ៊ុនមេត្តាដោះស្រាយដល់ប្រជាជនទៅតាមភាពជាក់ស្តែងទៅនឹងទំហំនៃការខូចខាត។
៩	លោក សុខ	មន្ត្រីពន្ធដារ ខេត្តកំពង់ស្ពឺ		✓		• លោកមានជាសំនួរ ទៅលើថាតើការអនុវត្តគម្រោងនេះ បានប៉ះពាល់ដល់វិស័យសេដ្ឋកិច្ចយ៉ាងណាខ្លះ?

Draft

	ចំណែន					• ការវាយតម្លៃដីធ្លី មិនមែនជាតួនាទីខាងពន្ធដារទេ។ តាមបទពិសោធន៍កន្លងមកត្រូវមានអង្គភាពអនុកម្មាការវាយតម្លៃ ជាអ្នកវាយតម្លៃដី គឺទាមទារឱ្យមានការចូលរួមពីមន្ទីរកសិកម្ម មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងពន្ធដារជាអ្នកយកពន្ធ។
១០	លោក ប៊ិន សំបាន	អនុប្រធានការិយាល័យរដ្ឋបាលមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់				• សូមឱ្យក្រុមហ៊ុន ធ្វើការសាងសង់បង្គោលដោយគោរពតាមច្បាប់រៀបចំដែនដីនគរូបនីយកម្ម។ • បើមានដីប៉ះពាល់សូមឱ្យមានការដោះស្រាយដោយសន្តិវិធី • សូមគាំទ្រ និងត្រៀមខ្លួនក្នុងការសហការជាមួយក្រុមហ៊ុនក្នុងការចុះដោះស្រាយដីប៉ះពាល់ប្រជាជន និងពេលសាងសង់។
១១	លោក គាន់ទីន	តំណាងក្រុមហ៊ុន Alex Corporation		✓		• គម្រោងខ្សែបញ្ជូនអគ្គិសនីនេះ ជាគម្រោងដែលត្រូវបានលើកទឹកចិត្តពីរាជរដ្ឋាភិបាល ហៅថា BOT (Build Operation Transfer) • ក្រុមហ៊ុនមានប្តង់រួចជាស្រេច ទាំងប្តង់បច្ចេកទេសក្នុងការសាងសង់បង្គោល និងខ្សែបញ្ជូន។ ម៉្យាងទៀតគម្រោងប្តង់អូសខ្សែបញ្ជូននេះ ក្រុមហ៊ុនបានសិក្សារួចជាស្រេច ដើម្បីបញ្ចៀសការប៉ះពាល់លំនៅដ្ឋាន និងតំបន់ទីប្រជុំជន។ • ពាល់ការប៉ះពាល់ទាំងឡាយក្រុមហ៊ុន Alex Corporation បានសហការជាមួយក្រុមហ៊ុន ទីប្រឹក្សាឯករាជដើម្បីវាយតម្លៃនូវការប៉ះពាល់ទាំងបរិស្ថាន និងសង្គម។

Draft



Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

						• ក្រុមហ៊ុនក៏មានផែនការកាត់បន្ថយនូវហេតុប៉ះពាល់ដែលអាចកើតមានដល់កម្រិតតិចបំផុត។ • គ្រប់មតិយោបល់ និងអនុសាសន៍ក្នុងអង្គប្រជុំនៅក្នុងថ្ងៃនេះ ខ្ញុំបាទនឹងដាក់ចូលកំណត់ហេតុ និងដាក់ជូនក្រុមហ៊ុនពិនិត្យ។

Draft


៥.៨ ការចូលរួមជាសាធារណៈជាមួយប្រជាជន

៥.៨.១ ការគាំទ្រពីប្រជាជនដែលរស់នៅក្បែរខ្សែបញ្ជូនអគ្គិសនី

តាមរយៈការសម្ភាសប្រជាជនដែលរងការប៉ះពាល់ ក្នុងឆ្នាំ២០១៥ ដោយសារការសាងសង់ខ្សែបញ្ជូនអគ្គិសនីបានបង្ហាញថាមានប្រជាជនប្រមាណ៨១,៨១ភាគរយ គាំទ្រចំពោះគម្រោងសាងសង់ខ្សែ បញ្ជូនអគ្គិសនី ខណៈពេលដែលប្រជាជនប្រមាណ១៨,១៩ភាគរយ មិនគាំទ្រចំពោះគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីរបស់ក្រុមហ៊ុន Alex Coporation នេះ។

ប្រជាជនខេត្តកំពង់ស្ពឺ មានការគាំទ្រ ៨១,១ភាគរយ ខណៈពេលដែលមាន១៨,៩ភាគរយ មិនគាំទ្រចំពោះការអភិវឌ្ឍគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីនេះ។ ចំពោះខេត្តកោះកុងដោយសារគម្រោងឆ្លងកាត់ ប្រមាណតែ២០គីឡូម៉ែត្រតែប៉ុណ្ណោះតាមការសម្ភាសប្រជាជនមួយចំនួនបានបង្ហាញថាគាត់មានការគាំទ្រ១០០ភាគរយចំពោះគម្រោងនេះ។ រីឯខេត្តព្រះសីហនុ តាមការសម្ភាសបានបង្ហាញថា មានប្រជាជនប្រមាណ៩១,២១ភាគរយ បានគាំទ្រលើគម្រោង ខណៈពេលដែលមាន៨,៧៩ភាគរយ មិនគាំទ្រចំពោះការសាងសង់គម្រោងខ្សែបញ្ជូននេះ។

ប្រជាជនដែលមានការគាំទ្រចំពោះការសាងសង់ខ្សែបញ្ជូនអគ្គិសនីនេះ ព្រោះពួកគាត់គិតថាគម្រោងនេះនឹងបានផ្តល់ថាមពលអគ្គិសនីសម្រាប់ផ្គត់ផ្គង់តម្រូវការរបស់ប្រជាជន ដែលធ្វើឱ្យប្រជាជនងាយស្រួលក្នុងការរស់នៅ និងប្រកបមុខរបរផ្សេងៗ។ ចំពោះប្រជាជនដែលមិនគាំទ្រចំពោះគម្រោងនេះព្រោះពួកគាត់គិតថា គម្រោងនេះនឹងធ្វើឱ្យមានការប៉ះពាល់ដល់ទ្រព្យសម្បត្តិប្រជាជនដូចជាលំនៅដ្ឋាន ស្រែចម្ការរបស់ពួកគាត់ ម្យ៉ាងទៀតក៏ធ្វើឱ្យមានការប៉ះពាល់ដល់សុខភាពប្រជាជនដែលរស់នៅក្បែរបង្គោលខ្សែបញ្ជូននេះផងដែរ។



ក្រាហ្វិក៥.១៖ ការគាំទ្ររបស់ប្រជាជនក្នុងខេត្តទាំងបី

Draft

៥.៨.២ ទស្សនៈប្រជាជនទាក់ទងនឹងគម្រោងខ្សែបញ្ជូនអគ្គិសនី

តាមរយៈការសម្ភាសគ្រួសារដែលរងការប៉ះពាល់ ក្នុងឆ្នាំ២០១៥ បានបង្ហាញថាពួកគាត់មានទស្សនៈពេញចិត្តចំពោះគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីនេះ ដែលការពេញចិត្តនេះ ភាគច្រើនគាត់សង្ឃឹមថាគម្រោងនេះនឹងផ្តល់សារៈប្រយោជន៍ជាច្រើនដល់សហគមន៍ និងប្រទេសជាតិរបស់យើងដូចជា៖

១. គម្រោងនេះនឹងផ្តល់ថាមពលអគ្គិសនីគ្រប់គ្រាន់
២. គម្រោងនេះនឹងផ្តល់ឱកាសដើម្បីឱ្យពួកគេអាចបង្កើតជំនួញដោយខ្លួនឯងបាន
៣. តម្លៃភ្លើង និងអាចថោកជាងមុន
៤. ងាយស្រួលក្នុងការបើកបរពេលយប់
៥. អាចរកប្រាក់ចំណូលបន្ថែមពីផលប៉ះពាល់វិជ្ជមានរបស់គម្រោង

ចំណែកគ្រួសារដែលរងការប៉ះពាល់ផ្សេងទៀត មានតែមួយចំនួនតូចប៉ុណ្ណោះដែលមិនពេញចិត្តទៅលើគម្រោងខ្សែបញ្ជូននេះព្រោះថា៖

១. គម្រោងនេះអាចធ្វើឱ្យបាត់បង់ដីរបស់ពួកគេ
២. កាត់បន្ថយប្រាក់ចំណូលពីការធ្វើស្រែចម្ការ
៣. អាចបាត់បង់ផ្ទះសម្បែង
៤. ទាមទារការសងសំណងដ៏សមរម្យលើដីដែលបានបាត់បង់
៥. តម្លៃដីធ្លាក់ចុះ
៦. តម្លៃភ្លើងឯកជនថ្លៃ។

៥.៩ ការចូលរួមពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន


យោងតាមការជួបសម្ភាសន៍ជាមួយអាជ្ញាធរមូលដ្ឋាន នៅខែមិនា ឆ្នាំ២០១៦ ក្នុងតំបន់គម្រោងទៅលើគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់២៣០គីឡូវ៉ុល បានបញ្ចេញមតិយោបល់ដូចខាងក្រោម៖

៥.៩.១ ការបញ្ចេញមតិយោបល់របស់លោកមេឃុំព្រះនិព្វាន

តាមរយៈការសម្ភាសលោកម៉ិច សារ៉ន មេឃុំព្រះនិព្វាន នៃស្រុកគងពិសី ខេត្តកំពង់ស្ពឺទៅលើគម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្យុងខ្ពស់២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ដែលមានទីតាំងពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយ៍អគ្គិសនីខាងលិចរាជធានីភ្នំពេញបានមានប្រសាសន៍ដូចខាងក្រោម៖

- លោកក៏បានដឹងពីគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតុងស្បុងខ្ពស់ ២៣០គីឡូវ៉ុលពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយខាងលិចរាជធានីភ្នំពេញផងដែរ។
- លោកបានបន្តទៀតថាគម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្បុងខ្ពស់នេះ បានប៉ះពាល់ចំនួនប៉ះពាល់ដីធ្លីរបស់ប្រជាជនចំនួន៩៧គ្រួសារ។
- ហើយលោកបានបន្តថា គម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីនេះមិនទាន់បានទូទាត់តម្លៃសំណងដីប៉ះពាល់ដល់ប្រជាជននៅឡើយទេ។ ចំពោះការទូទាត់សំណងលើដីប៉ះពាល់នេះគឺបច្ចុប្បន្នប្រជាជនរង់ចាំការសហការ និងធ្វើការចរចារដោយសន្តិវិធីជាមួយក្រុមហ៊ុនអភិវឌ្ឍន៍ក្នុងការដោះស្រាយសំណងជាក់ស្តែង ឱ្យបានសមស្របទៅតាមគោលនយោបាយដោយពួកគាត់មិនចង់យកសំណងលើសពីគោលការណ៍ជាក់ស្តែងឡើយ។
- លោកបានបញ្ជាក់ទៀតថាក្រៅពីក្រុមហ៊ុន Alex Corporation មិនមានប្រព័ន្ធបណ្តាញអគ្គិសនីក្រុមហ៊ុនដ៏ទៃទៀតឆ្លងកាត់ឃុំរបស់គាត់ទេ។
- ហើយលោកក៏មិនធ្លាប់បានដោះស្រាយសំណងផលប៉ះពាល់ នៅក្នុងឃុំរបស់គាត់ពីមុនមកដែរព្រោះថាក្នុងឃុំរបស់គាត់មិនទាន់មានគម្រោងអភិវឌ្ឍន៍ណា ដែលធ្វើឱ្យប៉ះពាល់ដល់ប្រជាជនដែលរស់នៅក្នុងឃុំរបស់គាត់ទេ។
- លោកបានសម្តែងនូវការគាំទ្រចំពោះគម្រោងអូសខ្សែបញ្ជូនអគ្គិសនី ពីអនុស្ថានីយ៍ស្ទឹងហាវទៅអនុស្ថានីយ៍ខាងលិចរាជធានីភ្នំពេញ ព្រោះគម្រោងនេះបានបម្រើផលប្រយោជន៍ជូនដល់ប្រជាជនក្នុងការប្រកបរបរអស់នៅប្រចាំថ្ងៃសម្រាប់ថ្ងៃអនាគត។ ជាពិសេសគម្រោងខ្សែបញ្ជូនអគ្គិសនីក៏បានផ្គត់ផ្គង់អគ្គិសនីបានគ្រប់គ្រាន់ទៅថ្ងៃអនាគតផងដែរ។ លើសពីនេះទៀតគម្រោងខ្សែបញ្ជូនអគ្គិសនីបានជួយសម្រួលដល់មុខរបរ និងការរស់នៅឱ្យមានលក្ខណៈល្អប្រសើរឡើង។
- លោកក៏បានសំណូមពរសូមឱ្យគម្រោងខ្សែបញ្ជូនអគ្គិសនីនេះ មានការសាងសង់ទៅតាមបច្ចេកទេសត្រឹមត្រូវផ្តោតទៅលើសុវត្ថិភាពដោយការពារកុំឱ្យឆក់ដល់ប្រជាជន ដែលរស់នៅក្បែរ និងក្នុងតំបន់គម្រោង រួមទាំងសូមឱ្យមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយទៅលើផលប៉ះពាល់ទាំងអស់នោះ។
- ជាចុងក្រោយលោកក៏បានបញ្ចេញមតិយោបល់សំណូមពរ សូមឱ្យមានការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជាពិសេសគឺផ្លូវថ្នល់។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



រូបភាព៥.២១៖ លោកម៉ិច សារ៉ន មេឃុំព្រះនិព្វាន

៥.៩.២ ការបង្ហាញមតិយោបល់របស់លោកមេឃុំសែនដី


តាមរយៈការសម្ភាសលោកប៉ិច កាន់ មេឃុំសែនដី នៃស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ទៅលើគម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្សុងខ្ពស់២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ដែលមានទីតាំងពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយ៍អគ្គិសនីខាងលិចរាជធានីភ្នំពេញបានមានប្រសាសន៍ដូចខាងក្រោម៖

- លោកក៏បានជ្រាបព័ត៌មានពីគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតុងស្សុងខ្ពស់ ២៣០គីឡូវ៉ុលពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយខាងលិចរាជធានីភ្នំពេញផងដែរ។
- លោកបានបន្តទៀតថាគម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្សុងខ្ពស់នេះ បានប៉ះពាល់ដីធ្លីរបស់ប្រជាជនចំនួន២០៧គ្រួសារ។
- ហើយលោកក៏បានបន្ថែមទៀតថា គម្រោងស្ថាងសង់ខ្សែបញ្ជូនអគ្គិសនីនេះមិនទាន់បានទូទាត់តម្លៃសំណងប៉ះពាល់ដល់ដីធ្លីរបស់ម្រជាជននៅឡើយទេ។ លោកបានបន្តថាចំពោះការទូទាត់សំណងលើដីប៉ះពាល់គឺបច្ចុប្បន្នប្រជាជនរង់ចាំការសហការ និងធ្វើការចរចារដោយសន្តិវិធីជាមួយក្រុមហ៊ុនអភិវឌ្ឍន៍ ក្នុងការដោះស្រាយសំណងជាក់ស្តែងឱ្យបានសម

Draft

ស្របទៅតាមគោលនយោបាយ ដោយពួកគាត់មិនចង់យកសំណងលើសពីគោលការណ៍ជាក់ស្តែងឡើយ។

- លោកបានបញ្ជាក់ទៀតថាក្រៅពីក្រុមហ៊ុន Alex Corporation ក៏នៅមានប្រព័ន្ធបណ្តាញអគ្គិសនីក្រុមហ៊ុនដ៏ទៃទៀតឆ្លងកាត់ឃុំរបស់គាត់ផងដែរ។
- ហើយលោកក៏មិនធ្លាប់បានដោះស្រាយសំណងផលប៉ះពាល់ នៅក្នុងឃុំរបស់គាត់ពីមុនមកដែរ ព្រោះថាក្នុងឃុំរបស់គាត់មិនទាន់មានគម្រោងអភិវឌ្ឍន៍ណាដែលធ្វើឱ្យប៉ះពាល់ដល់ប្រជាជនដែលរស់នៅក្នុងឃុំរបស់គាត់ទេ។
- លោកបានសម្តែងនូវការគាំទ្រចំពោះគម្រោងអូសខ្សែបញ្ជូនអគ្គិសនីតុងស្សុងខ្ពស់ ពីអនុស្ថានីយ៍ស្វឹងហាវ ទៅអនុស្ថានីយ៍ខាងលិចរាជធានីភ្នំពេញព្រោះគម្រោងនេះបានបម្រើផលប្រយោជន៍ជូនដល់ប្រជាជនក្នុងការប្រកបរបរអស់នៅប្រចាំថ្ងៃសម្រាប់ថ្ងៃអនាគត។ ជាពិសេសគម្រោងខ្សែបញ្ជូនអគ្គិសនី ក៏បានផ្តត់ផ្តង់អគ្គិសនីបានគ្រប់គ្រាន់ទៅថ្ងៃអនាគតផងដែរ។
- លោកក៏បានសំណូមពរសូមឱ្យគម្រោងខ្សែបញ្ជូនអគ្គិសនីនេះ មានការសាងសង់ទៅតាមបច្ចេកទេសត្រឹមត្រូវផ្តោតទៅលើសុវត្ថិភាពជាចម្បងដោយការពារកុំឱ្យឆក់ ដល់ប្រជាជនដែលរស់នៅក្បែរ និងក្នុងតំបន់គម្រោង និងចង់ឱ្យមានវគ្គបណ្តុះបណ្តាលខ្លីស្តីពីផលប៉ះពាល់ផ្សេងៗផងដែរ រួមទាំងសូមឱ្យមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយទៅលើផលប៉ះពាល់ទាំងអស់នោះ។
- ជាចុងក្រោយលោកក៏បានបញ្ចេញមតិយោបល់សំណូមពរ សូមឱ្យមានការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវថ្នល់ មន្ទីរពេទ្យ និងសូមឱ្យមានការជួសជុលឡើងវិញលើហេដ្ឋារចនាសម្ព័ន្ធដែលទទួលរងការខូចខាតជាពិសេសផ្លូវថ្នល់ជាដើម។



រូបភាព៥.២២៖ លោកប៉ិច កាន់ មេឃុំសែនដី


Draft

៤.៩.៣ ការបញ្ចេញមតិយោបល់របស់លោកមេឃុំក្រាំងអំពិល

តាមរយៈការសម្ភាសលោកមុី ខេត ជាមេឃុំក្រាំងអំពិល នៃស្រុកសំពោធទង ខេត្តកំពង់ស្ពឺ ទៅលើគម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្សុងខ្ពស់២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ដែលមានទីតាំងពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយ៍អគ្គិសនីខាងលិចរាជធានីភ្នំពេញបានមានមតិយោបល់ដូចខាងក្រោម៖

- លោកក៏បានដឹងពីគម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្សុងខ្ពស់២៣០គីឡូវ៉ុល ពីអនុស្ថានីយ៍ស្ទឹងហាវទៅអុស្ថានីយ៍ខាងលិចរាជធានីភ្នំពេញ
- លោកបានបញ្ជាក់ទៀតថា គម្រោងខ្សែបញ្ជូនអគ្គិសនីបានប៉ះពាល់លើដីធ្លីចំនួន២០ គ្រួសារ ចំពោះផលប៉ះពាល់លើដីធ្លីទាំងអស់នោះក្រុមហ៊ុនអភិវឌ្ឍន៍មិនទាន់បានទូទាត់តម្លៃសំណងដល់ប្រជាជនក្នុងឃុំនៅឡើយទេ។ សម្រាប់ការដោះស្រាយសំណងលើដីប៉ះពាល់ទាំងអស់នោះគឺប្រជាជនក្នុងឃុំរង់ចាំការទូទាត់សំណងមួយស្រប ទៅតាមគោលនយោបាយ និងការទូទាត់សំណងមួយដ៏សមរម្យឱ្យស្របទៅតាមតម្លៃទីផ្សារនាពេលបច្ចុប្បន្ន។
- លោកបានបន្តថាលោកមិនធ្លាប់ដោះស្រាយសំណងផលប៉ះពាល់ពីមុនៗមកទេ ព្រោះថាគម្រោងអភិវឌ្ឍន៍ទាំងនោះមិនដែលមានផលប៉ះពាល់ដល់ប្រជាជននោះទេ។
- លោកបានបន្ថែមទៀតថានៅមានប្រព័ន្ធបណ្តាញខ្សែបញ្ជូនអគ្គិសនីផ្សេងទៀត បានឆ្លងកាត់តំបន់មូលដ្ឋានរបស់គាត់ដែលជាប្រភេទខ្សែភ្លើងតូចៗ ប៉ុន្តែមិនមានផលប៉ះពាល់អ្វីដល់ដីធ្លីរបស់ប្រជាជនទេ។
- លើសពីនេះលោកបានគាំទ្រ និងពេញចិត្តទៅលើគម្រោងអភិវឌ្ឍន៍ខ្សែបញ្ជូនអគ្គិសនីតុងស្សុងខ្ពស់២៣០គីឡូវ៉ុល ព្រោះថាគម្រោងនេះនឹងផ្តត់ផ្តង់ថាមពលអគ្គិសនីគ្រប់គ្រាន់នៅក្នុងតំបន់មូលដ្ឋាននាពេលអនាគត និងជួយសម្រួលដល់មុខរបរប្រជាជនឱ្យមានការរស់នៅល្អប្រសើរសម្រាប់ពេលអនាគតផងដែរ។
- លោកបានសំណូមពរចុងក្រោយ ដល់ក្រុមហ៊ុនកុំឱ្យសាងសង់នៅរដូវវស្សាជៀសវាងការប៉ះពាល់លើការធ្វើស្រែចម្ការប្រជាជននៅតាមគន្លងខ្សែបញ្ជូនអគ្គិសនី និងមុនពេលសាងសង់សូមជួយជូនដំណឹងដល់ប្រជាជនឱ្យបានដឹងជាមុន ជៀសវាងការប៉ះពាល់ផ្សេងៗដូចជាមានគារឆក់អគ្គិសនីជាដើម។
- សម្រាប់យោបល់ចុងក្រោយលោកបានសំណើទៅក្រុមហ៊ុនអភិវឌ្ឍន៍ សូមជួយជាសម្ភារៈជាសម្ងាហភាពសម្រាប់ភូមិដែលប៉ះពាល់ និងសូមជួយជាស៊ីម៉ង់ផងដែរ។

Draft



Draft


រូបភាព៥.២៣៖ លោកម៉ី ខេត មេឃុំក្រាំងអំពិល

៤.៩.៤ ការបញ្ចេញមតិយោបល់របស់លោកមេឃុំស្ទុះ

តាមរយៈការសម្ភាសលោកញ៉ៅប ប៊ុននាង ជាមេឃុំស្ទុះ នៃស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ទៅលើគម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្សុងខ្ពស់២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ដែលមានទីតាំងពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយ៍អគ្គិសនីខាងលិចរាជធានីភ្នំពេញបានមានប្រសាសន៍ដូចខាងក្រោម៖

- លោកក៏ធ្លាប់បានដឹងពីគម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្សុងខ្ពស់២៣០គីឡូវ៉ុល ពីអនុស្ថានីយ៍ស្ទឹងហាវទៅអុស្ថានីយ៍ខាងលិចរាជធានីភ្នំពេញ
- លោកបានបញ្ជាក់ទៀតថា គម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្សុងខ្ពស់២៣០គីឡូវ៉ុលនេះ បានប៉ះពាល់លើដីធ្លីចំនួន៩១គ្រួសារគ្រាន់តែមានការប៉ះពាល់តិចតួចតែប៉ុណ្ណោះ ចំពោះផលប៉ះពាល់លើដីធ្លីទាំងអស់នោះក្រុមហ៊ុនអភិវឌ្ឍន៍ មិនទាន់បានទូទាត់តម្លៃសំណងដល់ប្រជាជនក្នុងឃុំនៅឡើយទេ។ សម្រាប់ការដោះស្រាយសំណងលើដីប៉ះពាល់ទាំងអស់នោះគឺប្រជាជនក្នុងឃុំរង់ចាំគណៈកម្មាការ ដើម្បីចុះមកជួបប្រជុំរវាងក្រុមហ៊ុនអភិវឌ្ឍន៍ និងប្រជាជន និងចង់បានការទូទាត់សំណងមួយសមរម្យ។

- លោកបានបន្តថា លោកមិនធ្លាប់បានដោះស្រាយសំណងផលប៉ះពាល់ពីមុនៗមកទេ ព្រោះថាគម្រោងអភិវឌ្ឍន៍ទាំងនោះ មិនដែលមានផលប៉ះពាល់ដល់ប្រជាជននោះទេ។
- លោកបានបញ្ជាក់ថាក្នុងតំបន់មូលដ្ឋានរបស់គាត់ មិនមានបណ្តាញអគ្គិសនីរបស់ក្រុមហ៊ុនផ្សេងទៀតនោះទេ។
- លើសពីនេះលោកបានគាំទ្រ និងពេញចិត្តទៅលើគម្រោងអភិវឌ្ឍន៍ខ្សែបញ្ជូនអគ្គិសនីតុងស្សុងខ្ពស់២៣០គីឡូវ៉ុល ព្រោះថាគម្រោងនេះនឹងផ្តត់ផ្តង់ថាមពលអគ្គិសនីគ្រប់គ្រាន់នៅក្នុងតំបន់មូលដ្ឋាន។
- លោកបានសំណូមពរចុងក្រោយដល់ក្រុមហ៊ុន កុំឱ្យសាងសង់នៅរដូវវស្សាជៀសវាងការប៉ះពាល់លើការធ្វើស្រែរបស់ប្រជាជន និងជាពិសេសសូមជួយជូនដំណឹងដល់ប្រជាជនឱ្យបានដឹងជាមុនជៀសវាងការប៉ះពាល់ផ្សេងៗដូចជាមានការឆក់អគ្គិសនីជាដើម។
- សម្រាប់ឃោបល់ចុងក្រោយលោកបានសូមឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ ជួយជាប្រលាយទឹកពីភ្នំមកចូលក្នុងឃុំ។



រូបភាព៥.២៩៖ លោកញ៉ែប ប៊ុននាង មេឃុំស្ទុះ


៤.៩.៤ ការបញ្ចេញមតិយោបល់របស់លោកមេឃុំធម្មតាអរ

យោងតាមរយៈការសម្ភាសលោកអែម ធន មេឃុំធម្មតាអរ នៃស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ទៅលើគម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្សុងខ្ពស់២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ដែលមានទីតាំងពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយ៍អគ្គិសនីខាងលិចរាជធានីភ្នំពេញបានមានមតិយោបល់ដូចខាងក្រោម៖

- លោកក៏បានជ្រាបព័ត៌មានពីគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតុងស្សុងខ្ពស់ ២៣០គីឡូវ៉ុលពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយខាងលិចរាជធានីភ្នំពេញផងដែរ។
- លោកបានបន្តទៀតថាគម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្សុងខ្ពស់នេះ បានប៉ះពាល់ដីធ្លីរបស់ប្រជាជនចំនួន១២៧គ្រួសារ។ សម្រាប់ការប៉ះពាល់លើដីធ្លីនេះមិនទាន់បានទូទាត់តម្លៃសំណងដល់ប្រជាជននៅឡើយទេ។ លោកបានបន្តថាចំពោះការទូទាត់សំណងលើដីប៉ះពាល់នេះ គឺប្រជាជនរង់ចាំការចូលរួមប្រជុំជាមួយក្រុមហ៊ុនអភិវឌ្ឍន៍ និងចង់ឱ្យមានការដោះស្រាយដោយស្របតាមគោលនយោបាយត្រឹមត្រូវ។
- លោកបានបន្ថែមទៀតថា មិនមានប្រព័ន្ធបណ្តាញខ្សែបញ្ជូនអគ្គិសនីឆ្លងកាត់ក្នុងតំបន់មូលដ្ឋានរបស់គាត់ទេ។
- លោកបន្តថាសម្រាប់គម្រោងអភិវឌ្ឍន៍ពីមុនក៏បានប៉ះពាល់ដល់ប្រជាជនផងដែរ ប៉ុន្តែមានការដោះស្រាយសំណងប៉ះពាល់ទទួលបានជោគជ័យ គឺប្រជាជនទទួលបានសំណងសមស្រប និងមានការឯកភាពគ្នារវាងប្រជាជនជាមួយនឹងក្រុមហ៊ុនអភិវឌ្ឍន៍។
- លោកបានសម្តែងនូវការគាំទ្រចំពោះគម្រោងអូសខ្សែបញ្ជូនអគ្គិសនី ពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយ៍ខាងលិចរាជធានីភ្នំពេញ. ព្រោះថាគម្រោងខ្សែបញ្ជូននេះបានផ្គត់ផ្គង់ថាមពលអគ្គិសនីគ្រប់គ្រាន់ក្នុងតំបន់ និងជួយសម្រួលដល់មុខរបរដែលធ្វើឱ្យការរស់នៅឱ្យមានលក្ខណៈល្អប្រសើរ។
- លោកក៏បានសំណូមពរដល់ក្រុមហ៊ុនអភិវឌ្ឍន៍ធ្វើយ៉ាងណា ជួយដោះស្រាយលើការទូទាត់សំណងឱ្យបានសមស្របដល់ប្រជាជន។
- សម្រាប់មតិយោបល់ចុងក្រោយ គឺលោកបានសំណើឱ្យក្រុមហ៊ុនជួយអភិវឌ្ឍន៍លើហេដ្ឋារចនាសម្ព័ន្ធដូចជាជួសជុលលើផ្លូវលំ និងស្ពារស្រះជាដើម។

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



រូបភាព៥.២៥៖ លោកអែម ធន មេឃុំធម្មតាអរ

Draft


៥.៩.៦ ការបញ្ចេញមតិឃោសនៈរបស់ជំទប់ទី១ឃុំមហាសាំង

តាមរយៈការសម្ភាសលោកតៅ លន់ ជំទប់ទី១ នៃឃុំមហាសាំង នៃស្រុកក្អមស្រូច ខេត្តកំពង់ស្ពឺ ទៅលើគម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្បុងខ្ពស់២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ដែលមានទីតាំងពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយ៍អគ្គិសនីខាងលិចរាជធានីភ្នំពេញបានមានប្រសាសន៍ដូចខាងក្រោម៖

- លោកក៏ធ្លាប់បានដឹងពីគម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្បុងខ្ពស់២៣០គីឡូវ៉ុល ពីអនុស្ថានីយ៍ស្ទឹងហាវទៅអនុស្ថានីយ៍ខាងលិចរាជធានីភ្នំពេញ។
- លោកបានបញ្ជាក់ទៀតថា គម្រោងខ្សែបញ្ជូនអគ្គិសនីបានប៉ះពាល់លើដីធ្លីចំនួន៣៥គ្រួសារ ចំពោះផលប៉ះពាល់លើដីធ្លីទាំងអស់នោះក្រុមហ៊ុនអភិវឌ្ឍន៍មិនទាន់បានទូទាត់តម្លៃសំណងដល់ប្រជាជនក្នុងឃុំនៅឡើយទេ។ ការដោះស្រាយលើការទូទាត់សំណងលើដីប៉ះពាល់នេះ គឺប្រជាជនចង់បានការទូទាត់សំណងមួយដ៏សមស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដោយស្របនឹងតម្លៃជំនួសលើទីផ្សារ។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

- លោកបានបន្តថាក្នុងឃុំមហាសាំងមិនធ្លាប់មានគម្រោងអភិវឌ្ឍន៍ណាពីមុន ដែលមានផលប៉ះពាល់ដល់ប្រជាជននោះទេ ដូចនេះលោកក៏មិនធ្លាប់បានដោះស្រាយសំណងប៉ះពាល់ពីមុនៗមកដែរ។
- លោកបានបញ្ជាក់ថាក្នុងតំបន់មូលដ្ឋានរបស់គាត់ មិនមានបណ្តាញអគ្គិសនីរបស់ក្រុមហ៊ុនផ្សេងទៀតនោះទេ។
- លើសពីនេះលោកបានគាំទ្រ និងពេញចិត្តទៅលើគម្រោងអភិវឌ្ឍន៍ខ្សែបញ្ជូនអគ្គិសនីតុងស្សុងខ្ពស់២៣០គីឡូវ៉ុល ព្រោះថាគម្រោងនេះនឹងផ្តត់ផ្តង់ថាមពលអគ្គិសនីគ្រប់គ្រាន់នៅក្នុងតំបន់មូលដ្ឋាន។
- លោកបានសំណូមពរ ដល់រាជរដ្ឋាភិបាលធ្វើយ៉ាងណាការពារផលប៉ះពាល់របស់ប្រជាជន និងសូមបើកវគ្គបណ្តុះបណ្តាលខ្លីស្តីពីការប៉ះពាល់ផ្សេងៗដូចជាការឆក់ជាដើមដើម្បីការពារកុំឱ្យភ័យខ្លាច។
- មតិយោបល់របស់លោក គឺចង់ឱ្យក្រុមហ៊ុនជួយអភិវឌ្ឍន៍ផ្នែកប្រព័ន្ធធារាសាស្ត្រព្រោះពាល់ថ្ងៃអាចប្រឈមនឹងការខ្វះខាតទឹកប្រើប្រាស់។



រូបភាព៥.២៦៖ លោកតៅ លន់ ជំទប់ទី១ឃុំមហាសាំង

៤.៩.៧ ការបញ្ចេញមតិយោបល់របស់លោកមេឃុំគីរីវន្ត

តាមរយៈការសម្ភាសលោកស៊ីន គឿន ជាមេឃុំគីរីវន្ត នៃស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ទៅលើគម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្ស៊ុងខ្ពស់២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ដែលមានទីតាំងពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយ៍អគ្គិសនីខាងលិចរាជធានីភ្នំពេញបានមានប្រសាសន៍ដូចខាងក្រោម៖

- លោកបានដឹងពីគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតុងស្ស៊ុងខ្ពស់ ២៣០គីឡូវ៉ុលពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយខាងលិចរាជធានីភ្នំពេញ។
- លោកបានបន្តទៀតថា គម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្ស៊ុងខ្ពស់នេះបានប៉ះពាល់ដីធ្លីរបស់ប្រជាជនចំនួន៥៥គ្រួសារ។
- ហើយលោកបានបន្តថា ចំពោះការប៉ះពាល់លើដីធ្លីដោយសារគម្រោងខ្សែបញ្ជូនអគ្គិសនីនេះគឺក្រុមហ៊ុនអភិវឌ្ឍន៍នៅមិនទាន់បានទូទាត់តម្លៃសំណងដីប៉ះពាល់ ដល់ប្រជាជននៅឡើយទេ។ លោកបានបន្តថាចំពោះការទូទាត់សំណងលើដីប៉ះពាល់គឺចង់បានការដោះស្រាយមួយដោយសមស្របតាមគោលការណ៍ច្បាប់។
- លោកបានបញ្ជាក់ទៀតថា នៅក្នុងតំបន់មូលដ្ឋានរបស់គាត់មិនមានប្រព័ន្ធបណ្តាញខ្សែបញ្ជូនអគ្គិសនីឆ្លងកាត់នោះទេ។
- លោកក៏បានមានប្រសាសន៍ទៀតថា ក្នុងឃុំរបស់គាត់ក៏មានគម្រោងអភិវឌ្ឍន៍ដ៏ទៃទៀតដែលមានការប៉ះពាល់ ដល់ប្រជាជនផងដែរលោកបានដោះស្រាយដោយជម្រាបជូនដំណឹងដល់ប្រជាជនដែលប៉ះពាល់ឱ្យបានដឹងមុន រួមទាំងប្រជាជនក៏បានដោះស្រាយដោយសន្តិវិធីដោយមិនមានជំទាស់អ្វីដែរ។
- លោកបានសម្តែងនូវការគាំទ្រ ចំពោះគម្រោងអូសខ្សែបញ្ជូនអគ្គិសនីពីអនុស្ថានីយ៍ស្ទឹងហាវទៅអនុស្ថានីយ៍ខាងលិចរាជធានីភ្នំពេញ ព្រោះក្នុងឃុំរបស់គាត់ត្រូវការភ្លើងការផ្គត់ផ្គង់ភ្លើងអគ្គិសនីបន្ថែម។
- លោកសំណូមពរដល់ក្រុមហ៊ុនសូមឱ្យគម្រោងខ្សែបញ្ជូនអគ្គិសនីនេះ មានការសាងសង់ទៅតាមបច្ចេកទេសត្រឹមត្រូវ និងសុវត្ថិភាពជាចម្បងព្រោះខ្លាចឆក់ដល់ប្រជាជនដែលរស់នៅក្បែរ និងក្នុងតំបន់គម្រោង។
- ជាចុងក្រោយមតិយោបល់របស់លោក គឺលោកសូមឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ជួយអភិវឌ្ឍន៍មូលដ្ឋានលើផ្នែកប្រព័ន្ធភ្លើង។

Draft



រូបភាព៥.២៧៖ លោកសុិន គឿន មេឃុំគីរីវន្ត

Draft

៥.៩.៨ ការបញ្ជាញមតិឃោបល់របស់លោកស្រីមេឃុំអូរ

តាមរយៈការសម្ភាសលោកស្រីតាំង គឹមចេង មេឃុំអូរ នៃស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ទៅលើគម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្បុងខ្ពស់២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ដែលមានទីតាំងពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយ៍អគ្គិសនីខាងលិចរាជធានីភ្នំពេញបានមានប្រសាសន៍ដូចខាងក្រោម៖

- លោកស្រីក៏បានដឹងពីគំរោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតុងស្បុងខ្ពស់ ២៣០គីឡូវ៉ុលពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយខាងលិចរាជធានីភ្នំពេញផងដែរ។
- លោកស្រីបានមន្តទៀតថាគម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្បុងខ្ពស់នេះ បានប៉ះពាល់ដីធ្លីរបស់ប្រជាជនចំនួន១២ផ្ទះគ្រួសារ។
- ហើយលោកស្រីបានបន្តែមថា ក្នុងឃុំរបស់គាត់មិនទាន់បានទូទាត់តម្លៃសំណងដីប៉ះពាល់ដល់ប្រជាជននៅឡើយទេ។ ហើយលោកស្រីបានបន្តថាសម្រាប់ការដោះស្រាយលើសំណងដីប៉ះពាល់ប្រជាជនចង់បានការដោះស្រាយសំណងសមស្របទៅនឹងតម្លៃទីផ្សារ។

- លោកស្រីបានបញ្ជាក់ទៀតថាក្រៅពីក្រុមហ៊ុន Alex Corporation ក៏នៅមានប្រព័ន្ធបណ្តាញអគ្គិសនីក្រុមហ៊ុនដ៏ទៃទៀតឆ្លងកាត់ឃុំរបស់គាត់ផងដែរ ហើយបណ្តាញអគ្គិសនីដែលបានឆ្លងកាត់នេះក៏បានប៉ះពាល់បន្តិចបន្តួចដល់ប្រជាជនផងដែរ។
- ហើយលោកស្រីបានបន្តទៀតថា គម្រោងអភិវឌ្ឍន៍ពីមុនក៏មានប៉ះពាល់ដល់ប្រជាជនក្នុងតំបន់មូលដ្ឋានផងដែរ តែការដោះស្រាយលើផលប៉ះពាល់នេះគឺចូលរួមសហការរវាងប្រជាជន និងក្រុមហ៊ុនអភិវឌ្ឍន៍ដោយដោះស្រាយសំណងដោយសន្តិវិធីស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃតម្លៃទីផ្សារបច្ចុប្បន្ន។
- លោកស្រី បានសម្តែងនូវការគាំទ្រចំពោះគម្រោងអូសខ្សែបញ្ជូនអគ្គិសនីពីអនុស្ថានីយ៍ស្វាយហាវ ទៅអនុស្ថានីយ៍ខាងលិចរាជធានីភ្នំពេញព្រោះគម្រោងខ្សែបញ្ជូនអគ្គិសនីនឹងផ្តត់ផ្តង់អគ្គិសនីបានគ្រប់គ្រាន់ទៅថ្ងៃអនាគតផងដែរ។
- លោកស្រីក៏បានសំណូមពរ សូមឱ្យគម្រោងខ្សែបញ្ជូនអគ្គិសនីនេះមានការសាងសង់ឱ្យមានសុវត្ថិភាពជូនដល់ប្រជាជន និងចង់ឱ្យមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយទៅលើផលប៉ះពាល់ទាំងអស់នោះផងដែរ។
- សម្រាប់មតិយោបល់របស់គាត់គឺសូមឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ជួយធ្វើទំនប់ និងធ្វើស្រះ។



Draft

រូបភាព៥.២៨៖ លោកស្រីតាំង គឹមចេង មេឃុំអូរ


៤.៩.៩ ការបញ្ចេញមតិយោបល់របស់ជំទប់ទី២នៃឃុំកែវផុស

តាមរយៈការសម្ភាសលោកវ៉ែន ណែន ជំទប់ទី២ នៃឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ទៅលើគម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្បូងខ្ពស់២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ដែលមានទីតាំងពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយ៍អគ្គិសនីខាងលិចរាជធានីភ្នំពេញបានមានមតិយោបល់ដូចខាងក្រោម៖

- លោកបានជ្រាបពីគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតុងស្បូងខ្ពស់ ២៣០គីឡូវ៉ុលពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយខាងលិចរាជធានីភ្នំពេញ។
- លោកបានបន្តទៀតថា គម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្បូងខ្ពស់នេះបានប៉ះពាល់ដីធ្លីរបស់ប្រជាជនចំនួន៣ភូមិ។
- ហើយលោកបានបន្ថែមថា ក្នុងការសាងសង់គម្រោងខ្សែបញ្ជូនអគ្គិសនីក្នុងឃុំកែវផុសនេះបានទូទាត់តម្លៃសំណងដីប៉ះពាល់ដល់ប្រជាជនរួចរាល់ហើយ។ ការដោះស្រាយសំណងលើដីប៉ះពាល់នេះគឺមានការពិគ្រោះយោបល់រវាងប្រជាជន និងក្រុមហ៊ុនអភិវឌ្ឍន៍ដោយដោះស្រាយសំណងដីប៉ះពាល់សមស្របទៅនឹងតម្លៃទីផ្សារ និងដោយសន្តិវិធី។
- លោកបានបញ្ជាក់ទៀតថាក្រៅពីក្រុមហ៊ុន Alex Corporation មិនមានប្រព័ន្ធបណ្តាញអគ្គិសនីក្រុមហ៊ុនផ្សេងទៀតឆ្លងកាត់តំបន់មូលដ្ឋានរបស់គាត់ទេ។
- ហើយយុទ្ធសាស្ត្រក្នុងការដោះស្រាយសំណងដីប៉ះពាល់ ដែលធ្លាប់ឆ្លងកាត់ពីមុនមកគឺការដោះស្រាយដោយសន្តិវិធីរវាងប្រជាជន និងក្រុមហ៊ុនអភិវឌ្ឍន៍។
- លោកបានសម្តែងនូវការគាំទ្រចំពោះគម្រោងអូសខ្សែបញ្ជូនអគ្គិសនី ពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយ៍ខាងលិចរាជធានីភ្នំពេញ ព្រោះគម្រោងខ្សែបញ្ជូនអគ្គិសនីនឹងផ្តត់ផ្គង់អគ្គិសនីបានគ្រប់គ្រាន់ទៅថ្ងៃអនាគត និងធ្វើឱ្យតម្លៃអគ្គិសនីអាចនឹងធ្លាក់ចុះក្នុងតំបន់មូលដ្ឋានរបស់គាត់។
- ជាចុងក្រោយលោកគ្មានសំណូមពរ និងមតិយោបល់ក្នុងការស្នើសុំអ្វីទេព្រោះតំបន់មូលដ្ឋានរបស់គាត់ជាតំបន់អភិវឌ្ឍន៍

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com



Draft

រូបភាព៥.២៩៖ លោកវ៉ែន ណែន ជំទប់ទី២ ឃុំកែវជុំស

៥.៩.១០ ការបញ្ជាក់មតិយោបល់របស់លោកមេភូមិស្ទឹងឆាយ នៃឃុំបឹងព្រាវ

តាមរយៈការសម្ភាសលោកមេភូមិស្ទឹងឆាយ តាំង ហោងហួរ នៃឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង ទៅលើគម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្សុងខ្ពស់២៣០គីឡូវ៉ុលរបស់ក្រុមហ៊ុន Alex Corporation ដែលមានទីតាំងពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយ៍អគ្គិសនីខាងលិចរាជធានីភ្នំពេញបានមានប្រសាសន៍ដូចខាងក្រោម៖

- លោកបានដឹងពីគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីតុងស្សុងខ្ពស់ ២៣០គីឡូវ៉ុលពីអនុស្ថានីយ៍ស្ទឹងហាវ ទៅអនុស្ថានីយខាងលិចរាជធានីភ្នំពេញផងដែរ។
- លោកបានបន្តទៀតថាគម្រោងខ្សែបញ្ជូនអគ្គិសនីតុងស្សុងខ្ពស់នេះ បានប៉ះពាល់ដីធ្លីរបស់ប្រជាជនចំនួន៤២គ្រួសារ។ ហើយលោកបានបន្ថែមថាគម្រោងសាងសង់ខ្សែបញ្ជូនអគ្គិសនីនេះមានការទូទាត់តម្លៃសំណងដីប៉ះពាល់រួចរាល់ហើយគឺមានការដោះស្រាយសមស្របទៅ